Unofficial Translation

# សេចក្តីសន្និដ្ឋាន និង/ឬអនុសាសន៍

ប្រទេសកម្ពុជានឹងពិនិត្យមើលអនុសាសន៍ទាំងអស់ខាងក្រោមនេះ រួចនឹងផ្តល់ការឆ្លើយតបក្នុងពេលវេលាមួយសមស្របនៅមុនសម័យប្រជុំលើកទី៤១ របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស៖

១. អនុលោមតាមកាតព្វកិច្ចក្រោមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចូរធ្វើការពិភាក្សាឱ្យបានល្អិតល្អន់លើការអនុវត្ត និងការកែលម្អគោលនយោបាយ និងបទប្បញ្ញត្តិផ្សេងៗ(អ៊ុយក្រែន)។

២. ពិចារណាលើការទទួលយកលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិ ដែលកម្ពុជាមិនទាន់ក្លាយជារដ្ឋភាគី (ហុងឌូរ៉ាស)។

៣. បន្តស្វែងរកលទ្ធភាព ដើម្បីពង្រីកវិសាលភាពនៃការប្តេជ្ញាចិត្តជាអន្តរជាតិរបស់ខ្លួន តាមរយៈការផ្តល់សច្ចាប័នលើពិធីសារបន្ថែមនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយដូចដែលបានផ្តល់អនុសាសន៍កាលពីពេលមុន (ទ្បេតូនី)។

៤. ទទួលយកពិធីសារបន្ថែម នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ(កូស្តារីកា)។

៥. ទទួលយកពិធីសារបន្ថែមទីពីរនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលមានគោលបំណងលុបចោលទោសប្រហារជីវិត(កូឡុំប៊ី); ផ្តល់សច្ចាប័នលើពិធីសារបន្ថែម នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលមានគោលបំណងលុបចោលទោសប្រហារជីវិត(បែលហ្ស៊ិក),(ម៉ុងតេណេហ្គ្រោ),(អ៊ុយក្រែន)។

៦. ផ្តល់សច្ចាប័នលើពិធីសារបន្ថែមទីពីរនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលមានគោលបំណង លុបចោលទោសប្រហារជីវិត និងចាត់វិធានការផ្សេងៗដើម្បីលុបចោលទោសប្រហារជីវិត(ម៉ិកស៊ិក)។

៧. ទទួលយកពិធីសារបន្ថែមនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយពាក់ព័ន្ធនឹងបណ្តឹងបុគ្គល (បេណាំង)។

៨. ពិចារណាលើការផ្តល់សច្ចាប័នអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ (ហ្វីលីពីន)។

៩. ពិចារណាលើការផ្តល់សច្ចាប័នអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ (អេហ្ស៊ីប)។

១០. ទទួលយកអនុសញ្ញាឆ្នាំ១៩៥៤ ពាក់ព័ន្ធនឹងឋានៈរបស់ជនគ្មានសញ្ជាតិ និងអនុសញ្ញាឆ្នាំ១៩៦១ ស្តីពីការកាត់បន្ថយភាពគ្មានសញ្ជាតិ(បេណាំង)។

១១. ចេញលិខិតអញ្ជើញអចិន្ត្រៃយ៍មួយ ដល់នីតិវិធីពិសេសអង្គការសហប្រជាជាតិ និងសហប្រតិបត្តិការក្នុងន័យ ស្ថាបនាជាមួយអ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ព្រមទាំងការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា (អាល្លឺម៉ង់)។

១២. ធ្វើវិសោធនកម្មច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីឱ្យស្របនឹងកាតព្វកិច្ចកម្ពុជាក្រោមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ក្រិក)។

១៣. ទទួលយកសំណើសុំធ្វើទស្សនកិច្ចពីអ្នកកាន់អាណត្តិនីតិវិធីពិសេស(ហុងដូរ៉ាស)។

១៤. អនុវត្តឱ្យបានពេញលេញ នូវអនុសាសន៍ទាំងអស់នៅក្នុងរបាយការណ៍ចុងក្រោយរបស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាព សិទ្ធិមនុស្សនៅកម្ពុជា រួមទាំងក្នុងរបាយការណ៍បន្ថែមរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (នូវែលសេឡង់)។

១៥. ចេញលិខិតអញ្ជើញអចិន្ត្រៃយ៍មួយដល់នីតិវិធីពិសេសទាំងអស់របស់អង្គការសហប្រជាជាតិ និងចូលរួមក្នុងន័យស្ថាបនាជាមួយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស និងនីតិវិធីពិសេសអង្គការសហប្រជាជាតិ(ក្រូអាស៊ី)។

១៦. ចេញលិខិតអញ្ជើញអចិន្ត្រៃយ៍មួយដល់នីតិវិធីពិសេសទាំងអស់របស់អង្គការសហប្រជាជាតិ(អ៊ុយក្រែន)។
១៧. ពង្រឹងកិច្ចសហការជាមួយនីតិវិធីពិសេសរបស់អង្គការសហប្រជាជាតិ ចេញ និងអនុវត្តការអញ្ជើញអចិន្ត្រៃយ៍មួយដល់នីតិវិធីពិសេសទាំងអស់នៅមុន UPR ជុំបន្ទាប់ (សាធារណរដ្ឋឆែក)។
១៨. ពង្រឹងកិច្ចសហការជាមួយនីតិវិធីពិសេសរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស តាមរយៈការឆ្លើយតបជាវិជ្ជមានចំពោះសំណើសុំធ្វើទស្សនកិច្ច ដែលមិនទាន់បានបញ្ចប់របស់អ្នកកាន់អាណត្តិនីតិវិធីពិសេស និងពិចារណាក្នុងការចេញលិខិត អញ្ជើញអចិន្ត្រៃយ៍មួយដល់អ្នកកាន់អាណត្តិនីតិវិធីពិសេសទាំងអស់ ដូចបានផ្តល់អនុសាសន៍កាលពីពេលកន្លងមក (ទ្បេតូនី)។
១៩. ចូលរួមក្នុងន័យស្ថាបនាជាមួយនីតិវិធីពិសេសទាំងអស់របស់អង្គការសហប្រជាជាតិ (អ៊ីតាលី)។
២០. បញ្ចប់កំណែទម្រង់ដីធ្លី ដើម្បីសម្រួលដល់ការទទួលបាន ការប្រើប្រាស់ និងការអភិវឌ្ឍដីសម្រាប់ក្រុមបុគ្គល និងសហគ្រាសខ្នាតតូច និងមធ្យម (សេនេហ្គាល់)។
២១. ចាត់វិធានការដើម្បីបង្កភាពងាយស្រួលក្នុងការបែងចែកដីសម្បទានសហគមន៍ដល់ជនជាតិដើមភាគតិច (តូហ្គោ)។
២២. អនុវត្តគោលនយោបាយតាំងលំនៅថ្មីស៊ីសង្វាក់គ្នា និងធ្វើឱ្យនីតិវិធីមានភាពងាយស្រួលសម្រាប់ ការផ្តល់បណ្ណកម្មសិទ្ធិដីធ្លីសហគមន៍ ដោយធ្វើការពិភាក្សាជាមួយសហគមន៍ សង្គមស៊ីវិល និងជនជាតិដើមភាគតិច (ចក្រភពអង់គ្លេស និងអៀរឡង់ខាងជើង)។
២៣. ធានាថា រាល់ទំនាស់ដីធ្លីដែលមិនទាន់បានបញ្ចប់ ការបណ្តេញចេញ និងការតាំងលំនៅថ្មី ត្រូវបានដោះស្រាយប្រកបដោយលក្ខណៈត្រឹមត្រូវ មានតម្លាភាព មានការចរចា និងមានការផ្តល់សំណងសមរម្យ (អូស្ត្រាលី)។
២៤. ចាត់វិធានការចាំបាច់នានា ដើម្បីបង្កើតឡើងវិញនូវបរិយាកាសមួយ ដែលមានការគោរព ដោយពេញលេញនូវសិទ្ធិរបស់សង្គមស៊ីវិល ដូចជា តាមរយៈការកែសម្រួលច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលជាដើម (បារាំង)។
២៥. ធ្វើវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់ស្តីពីសមគមនិងអង្គការមិនមែនរដ្ឋាភិបាល ដោយមានការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធផ្សេងៗ និងសង្គមស៊ីវិល ដែលបានរងផលប៉ះពាល់ ដើម្បីឱ្យច្បាប់ទាំងនេះស្របទៅនឹងកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិ(អាល្លឺម៉ង់)។
២៦. ធ្វើឱ្យច្បាប់ផ្សេងៗ ដូចជា ច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ច្បាប់សហជីព ច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់ទូរគមនាគមន៍ឱ្យស្របទៅនឹងកាតព្វកិច្ចអន្តរជាតិ (អ៊ីស្លង់)។
២៧. ធ្វើវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ ច្បាប់សហជីព និងច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីឱ្យច្បាប់ទាំងនេះស្របនឹងកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិរបស់កម្ពុជា ដោយធ្វើការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធផ្សេងៗ និងសង្គមស៊ីវិលដែលបានរងផលប៉ះពាល់(នូវែលសេឡង់)។
២៨. ការពារអង្គការមិនមែនរដ្ឋាភិបាលនិងសមាគមនានា ព្រមទាំងធានាថា បទប្បញ្ញត្តិរដ្ឋបាលនៃច្បាប់ស្តីពីសមគម និងអង្គការមិនមែនរដ្ឋាភិបាលនឹងមិនត្រូវបានប្រើដើម្បីបិទ ព្យួរ ឬជះឥទ្ធិពលអវិជ្ជមានទៅលើអង្គការមិនមែនរដ្ឋាភិបាល និងសមាគម (ស្លូវេនី)។
២៩. ពិនិត្យកែលម្អក្រមព្រហ្មទណ្ឌ ក៏ដូចជាច្បាប់ដទៃៗទៀត ដើម្បីឱ្យស្របទៅនឹងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ រួមមានច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ច្បាប់សហជីព និងច្បាប់ទូរគមនាគមន៍ដែលស្ថិតក្នុងការរងចាំ (សាធារណរដ្ឋឆេក)។
៣០. លុបចោលការធ្វើវិសោធនកម្មចំនួនពីរ លើច្បាប់ស្តីពីគណបក្សនយោបាយដែលបានអនុម័តក្នុងឆ្នាំ២០១៧ ពិនិត្យមើលឡើងវិញនូវច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល និងពិនិត្យច្បាប់សហជីព ដើម្បីធានាថាច្បាប់ទាំងបីនេះ

មានសង្គតិភាពជាមួយនឹងកាតព្វកិច្ចរបស់កម្ពុជា ក្រោមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (អូស្ត្រាលី)។

៣១. កែលម្អ ឬលុបចោលបទដ្ឋានគតិយុត្តថ្មីៗមួយចំនួន ដែលមានវត្ថុបំណងធ្វើការ បកស្រាយបែបរឹតត្បិត និងតាមទំនើងចិត្ត ដើម្បីធ្វើឱ្យច្បាប់ទាំងនេះស្របទៅនឹងច្បាប់ និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។ ក្នុងចំណោមច្បាប់ទាំងនោះ រួមមាន៖ ច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់បោះឆ្នោត ច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ព្រមទាំង ប្រកាស អន្តរក្រសួងកាលពីខែឧសភា ឆ្នាំ២០១៨ នៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម (អូស្ត្រាលី)។

៣២. បង្កើតក្រុមការងារយ៉ាងមានប្រសិទ្ធភាពមួយទទួលបន្ទុកទំនាស់ដីធ្លីក្រោមការគាំទ្ររបស់ក្រសួងដែនដី ដោយមានការចូលរួមពីសង្គមស៊ីវិល និងសហភាពអឺរ៉ុប (បារាំង)។

៣៣. បង្កើតគណៈកម្មាធិការត្រួតពិនិត្យថ្នាក់ជាតិលើសន្ធិសញ្ញាអន្តរជាតិនានា ដែលកម្ពុជាបានផ្តល់សច្ចាប័ន ដោយមានការចូលរួមរបស់អង្គការពលកម្មអន្តរជាតិ( បារាំង)។

៣៤. ពន្លឿននីតិវិធីអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិស្របទៅតាមគោលការណ៍ទីក្រុងប៉ារីស (ហ្សកហ្ស៊ី)។ ពន្លឿនការធ្វើពង្រាងច្បាប់ស្តីពីការបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិស្របទៅតាមគោលការណ៍ទីក្រុង ប៉ារីស (តូហ្គោ)។

៣៥. ពន្លឿនការបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិស្របទៅតាមគោលការណ៍ទីក្រុងបារីស(អាល់ហ្សេរី), (កូស្តារីកា)។ បង្កើនកិច្ចខិតខំប្រឹងប្រែងក្នុងការបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិស្របទៅតាមគោលការណ៍ទីក្រុងបារីស( ស៊ីលី)។

៣៦. បង្កើតស្ថាប័នសិទ្ធិមនុស្សជាតិឯករាជ្យមួយស្របទៅតាមគោលការណ៍ទីក្រុងប៉ារីស(អូស្ត្រាលី), (ម៉ិចស៊ិក)។

៣៧. បន្តកិច្ចខិតខំប្រឹងប្រែងក្នុងការបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិដូចចែងក្នុងគោលការណ៍ទីក្រុងប៉ារីស (នេប៉ាល់)។

៣៨. បន្តកិច្ចខិតខំប្រឹងប្រែង ដើម្បីចាប់ផ្តើមការងាររបស់ស្ថាប័នសិទ្ធិមនុស្សជាតិយោងទៅលើគោលការណ៍ទីក្រុងប៉ារីស (អ៊ីរ៉ាក់)។

៣៩. បន្តពង្រឹងកិច្ចខិតខំប្រឹងប្រែង ក្នុងការបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិស្របទៅតាមគោលការណ៍ទីក្រុងប៉ារីស (ឥណ្ឌូណេស៊ី)។

៤០. បន្តអនុវត្តអនុសាសន៍នានា ដែលបានទទួលយកក្រោមដំណើរការ UPR ឆ្នាំ២០១៤។ ជាពិសេស ការបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិមួយសម្រាប់ការលើកកម្ពស់ និងការការពារសិទ្ធិមនុស្សដោយមានធនធានគ្រប់គ្រាន់ (អេស្ប៉ាញ)។

៤១. ពន្លឿនដំណើរការក្នុងការបញ្ចប់ច្បាប់ស្តីពីការបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិស្របទៅតាមគោលការណ៍ទីក្រុងប៉ារីស (ថៃ)។

៤២.រក្សាកិច្ចខិតខំប្រឹងប្រែងបន្តទៀត ដើម្បីបង្កើតយន្តការសិទ្ធិមនុស្សជាតិស្របតាមគោលការណ៍ទីក្រុងប៉ារីស (ទុយនីស៊ី)។

៤៣. បញ្ចប់ឱ្យបានឆាប់រហ័សនូវនីតិវិធីនានា ពាក់ព័ន្ធទៅនឹងការបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិស្របតាមគោលការណ៍ទីក្រុងប៉ារីស(អ៊ុយក្រែន)។

៤៤. បន្តកិច្ចខិតខំប្រឹងប្រែង ដើម្បីបញ្ចប់ច្បាប់ស្តីពីគណៈកម្មការសិទ្ធិមនុស្សជាតិ និងធ្វើឱ្យតួនាទីរបស់គណៈកម្មការនោះមានភាពសកម្ម(យេម៉ែន)។

៤៥. បង្កើតច្បាប់ប្រឆាំងការរើសអើង ដែលធានា និងហាមឃាត់យ៉ាងជាក់លាក់នូវរាល់ប្រភេទនៃការរើសអើង ដូចជាដោយសារទំនោរផ្លូវភេទ អត្តសញ្ញាណយេនឌ័រ និងលក្ខណៈភេទ (អ៊ីស្លង់)។

៤៦. បង្កើតច្បាប់ទទួលស្គាល់យេនឌ័រ (អ៊ីស្លង់)។

៤៧. ធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ដើម្បីធានាឱ្យមានសមភាពអាពាហ៍ពិពាហ៍សម្រាប់គូស្វាមីភរិយាដែលមានភេទដូចគ្នា (អ៊ីស្លង់)។

៤៨. បង្កើនកិច្ចខិតខំប្រឹងប្រែងក្នុងការប្រយុទ្ធនឹងការរើសអើងប្រឆាំងនឹងជនជាតិដើម និងជាតិសាសន៍ភាគតិច ព្រមទាំងបង្កើតផែនការសកម្មភាពជាតិប្រឆាំងនឹងការរើសអើងពូជសាសន៍(តូហ្គោ)។

៤៩. ពង្រឹងគោលនយោបាយដីធ្លី ដែលបានអនុម័តកាលពីឆ្នាំ២០១៥ ដែលចែងអំពីសមភាព និងសមធម៌យេនឌ័ររវាងបុរសនិងស្ត្រី ហើយគួរតែត្រូវបានធានានៅក្នុងដំណើរការនៃការចុះបញ្ជីដីធ្លី(បូលីវី)។

៥០. ពិគ្រោះយោបល់ជាមួយអង្គការសង្គមស៊ីវិល ដើម្បីអនុម័តច្បាប់ និងគោលនយោបាយដែលគ្រប់ជ្រុងជ្រោយប្រឆាំងនឹងការរើសអើង និងអំពើហិង្សាដោយសារទំនោរផ្លូវភេទ ឬអត្តសញ្ញាណយេនឌ័រ និងធានាការអនុវត្តច្បាប់និងគោលនយោបាយទាំងនេះនៅក្នុងស្ថាប័នសាធារណៈទាំងអស់ ជាពិសេស ក្នុងវិស័យអប់រំ សុខាភិបាល និងការងារ (ម៉ិចស៊ិក)។

៥១. ធ្វើវិសោធនកម្មមាត្រា៤៥ នៃរដ្ឋធម្មនុញ្ញ ដើម្បីអនុញ្ញាតឱ្យមានសមភាពអាពាហ៍ពិពាហ៍ស្របច្បាប់ ជាមួយនឹងទស្សនៈក្នុងការបន្តនូវការប្រព្រឹត្តដោយស្មើភាពពេញលេញរបស់ក្រុមអ្នកស្រឡាញ់ភេទដូចគ្នានៅគ្រប់ស័យទាំងអស់ (ហូឡង់)។

៥២. បង្កើតច្បាប់ថ្មីមួយ ដែលធានានូវសមភាព និងហាមឃាត់យ៉ាងដាក់លាក់នូវការរើសអើងចំពោះក្រុមអ្នកស្រឡាញ់ភេទដូចគ្នា (ស៊ុយអែត)។

៥៣. អនុម័តវិធានការប្រកបដោយប្រសិទ្ធភាពក្នុងការប្រយុទ្ធប្រឆាំង និងផ្តន្ទាទោសចំពោះការរើសអើង និងអំពើហិង្សាដែលបានជំរុញដោយទំនោរផ្លូវភេទ និងអត្តសញ្ញាណយេនឌ័រ(អ៊ុយរូហ្គាយ)។

៥៤. ត្រឹមដំណាច់ឆ្នាំ២០២៣ ធ្វើការបង្កើតច្បាប់ប្រឆាំងការរើសអើង ដែលធានានូវសមភាព និងការហាមឃាត់យ៉ាងដាក់លាក់ពល់ការរើសអើងគ្រប់ប្រភេទ រួមមាន ដោយសារមូលដ្ឋាននៃសាសនា ទំនោរផ្លូវភេទ អត្តសញ្ញាណយេនឌ័រការសម្តែងចេញ និងលក្ខណៈភេទ (អូស្ត្រាលី)។

៥៥. ធ្វើវិសោធនកម្មមាត្រា៤៥ នៃរដ្ឋធម្មនុញ្ញ ដើម្បីអនុញ្ញាតឱ្យគូស្វាមីភរិយាមានភេទដូចគ្នារៀបការ(កាណាដា)។

៥៦. បន្តពង្រឹងគោលនយោបាយសង្គមដ៏ល្អរបស់ខ្លួន ដើម្បីជាប្រយោជន៍ប្រជាជន ដោយផ្តោតជាពិសេសទៅលើវិស័យនានា ដែលងាយរងគ្រោះបំផុត(វ៉េណេស៊ុយអេ ឡា)។

៥៧. បន្តរក្សាស្ថិរភាពសង្គម និងលើកកម្ពស់សេដ្ឋកិច្ច និងការអភិវឌ្ឍសង្គមប្រកបដោយចីរភាព ដើម្បីលើកកម្ពស់បទដ្ឋានរស់នៅរបស់ប្រជាជន និងបន្តកាត់បន្ថយអត្រានៃភាពក្រីក្របន្ថែមទៀត (ចិន)។

៥៨. បន្តយន្តការនានាដែលកំពុងអនុវត្ត ដើម្បីធានាការកាត់បន្ថយភាពក្រីក្រ(ឥណ្ឌា)។

៥៩. បន្តការចាត់វិធានការធានាការកាត់បន្ថយភាពក្រីក្រ និងការទទួលបានសេវាសុខាភិបាល និងអប់រំ(ប៉ាគីស្ថាន)។

៦០. បន្តវិនិយោគកិច្ចខិតខំប្រឹងប្រែងទៅលើការប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ តាមរយៈការអនុវត្តវិធានការនានា ដែលធ្វើឱ្យការអភិវឌ្ឍសេដ្ឋកិច្ចជាក់ស្តែងរបស់ប្រទេស ឆ្លុះបញ្ចាំងនៅគ្រប់កម្រិតទាំងអស់នៃសង្គម(ស៊ែប៊ី)។

៦១. បង្កើនកិច្ចខិតខំប្រឹងប្រែង ដើម្បីសម្រេចឱ្យបាននូវសិទ្ធិសេដ្ឋកិច្ចនិងសង្គមកិច្ចរបស់ប្រជាជន ជាពិសេស តាមរយៈកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងបរិយាប័ន្នសង្គម(អ៊ីរ៉ង់)។

៦២. បន្តអនុវត្តនយោបាយនានាក្នុងការលើកកម្ពស់កំណើនសេដ្ឋកិច្ច និងអនុវត្តកម្មវិធីដែលមានលក្ខណៈពេញលេញក្នុងការកាត់បន្ថយភាពក្រីក្រ (ម៉ាឡេស៊ី)។

៦៣.បន្តកិច្ចខិតខំប្រឹងប្រែងដើម្បីធ្វើឱ្យការលុបបំបាត់ភាពក្រីក្រកាន់តែប្រសើរឡើងជាពិសេសក្នុងតំបន់ដាច់ស្រយាល(គុយបា)។

៦៤. ចាត់វិធានការបន្ថែមទៀត ដើម្បីគាំពារ និងពង្រឹងវឌ្ឍនភាព ដែលសម្រេចបានក្នុងការកាត់បន្ថយភាពក្រីក្រ (វៀតណាម)។

៦៥. បន្តពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការល្អជាមួយដៃគូនានាបន្ថែមទៀត ដើម្បីអនុវត្តកម្មវិធីផ្សេងៗ ដែលមានគោលបំណងអភិវឌ្ឍន៍ជនបទ និងការកាត់បន្ថយភាពក្រីក្រប្រកបដោយប្រសិទ្ធភាព(អាស៊ែបៃហ្សង់)។

៦៦. បន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីសម្រេចឱ្យបាននូវគោលដៅទី៣ នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព(អាស៊ែបៃហ្សង់)។

៦៧. ខិតខំប្រឹងប្រែងកាន់តែខ្លាំងឡើង ដើម្បីកាត់បន្ថយភាពក្រីក្រ និងសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (ប៊ូតង់)។
៦៨. បន្តដោះស្រាយយ៉ាងមានប្រសិទ្ធភាពនូវភាពងាយរងគ្រោះបំផុត ទស្សនៈ និងតម្រូវការរបស់ស្ត្រី កុមារ ជន ពិការ ព្រមទាំងសហគមន៍មូលដ្ឋាន និងសហគមន៍បាត់បង់ឱកាស នៅពេលធ្វើការអនុវត្តផែនការ យុទ្ធសាស្ត្រជាតិស្តីពីការគ្រប់គ្រងហានិភ័យនៃគ្រោះមហន្តរាយដើម្បីសុខភាព និងផែនការយុទ្ធសាស្ត្របម្រែបម្រួលអាកាស ធាតុរបស់ខ្លួន(ហ្វីជី)។
៦៩. បង្កើនកិច្ចខិតខំប្រឹងប្រែងក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស(អ៊ីរ៉ាក់)។
៧០. បង្កើនកិច្ចខិតខំប្រឹងប្រែងក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស រួមទាំងស្ត្រី និងកុមារ (ហ្សកហ្ស៊ី)។
៧១. ពង្រឹងវិធានការនានា ដែលមានគោលបំណងក្នុងការបង្ការ និងប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស (ហុងឌូរ៉ាស)។
៧២. បន្តអនុវត្តយ៉ាងមានប្រសិទ្ធភាពនូវច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ(ហ្វីលីពីន)។
៧៣. ពង្រឹងកិច្ចខិតខំប្រឹងប្រែងក្នុងការអនុវត្តយ៉ាងមានប្រសិទ្ធភាពនូវច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ដើម្បីបង្ការ និងដោះស្រាយបញ្ហាជួញដូរមនុស្សឱ្យកាន់តែប្រសើរឡើង(ឥណ្ឌូណេស៊ី)។
៧៤. បន្តកិច្ចខិតខំប្រឹងប្រែងក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស(ទុយនីស៊ី)។
៧៥. កែលម្អ និងពង្រីកនីតិវិធីអត្តសញ្ញាណកម្ម និងការការពារដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការងារដោយបង្ខំនិងការងារដើម្បីដោះបំណុល និងធានាការទទួលបានគ្រប់គ្រាន់នូវសេវាគាំទ្រ និងទីជម្រកស្នាក់នៅ(ចក្រភពអង់គ្លេស និង អៀរឡង់ខាងជើង)។
៧៦. បន្តបង្កើនវិធានការផ្សេងៗដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស ជាពិសេសស្ត្រីនិងកុមារ ព្រមទាំងពង្រឹងវិធានការនានា ដើម្បីស្វែងរក បង្ការ និងផ្តន្ទាទោសបទល្មើសនេះ(វ៉េណេស៊ុយអេឡា)។
៧៧. ពង្រឹង និងសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស និងផ្តន្ទាទោសអ្នកជួញដូរទាំងនោះ(អាល់ហ្សេរី)។
៧៨. ផ្តល់ឱ្យឡើងវិញនូវសិទ្ធិទាំងឡាយដល់សមាជិកសមាជិកាបក្សប្រឆាំងទាំងអស់ភ្លាមៗ និងដោយគ្មានលក្ខខណ្ឌ ព្រមទាំងដោះលែងមនុស្សទាំងអស់ ដែលត្រូវបានឃុំខ្លួនដោយបំពាន រួមទាំង លោក កឹម សុខា(សហរដ្ឋអាមេរិក)។
៧៩. ធ្វើវិសោធនកម្មច្បាប់ និងបទប្បញ្ញត្តិនានា ដូចជា ច្បាប់ស្តីពីទូរគមនាគមន៍ និងប្រកាសអន្តរក្រសួងស្តីពីការត្រួតពិនិត្យការបោះពុម្ពផ្សាយរបស់គេហទំព័រ និងដំណើរការប្រព័ន្ធផ្សព្វផ្សាយសង្គមតាមអ៊ីនធឺណិត ដែលរឹតត្បិតយ៉ាងខ្លាំងដល់សេរីភាពក្នុងការបញ្ចេញមតិ ព្រមទាំងដើម្បីបញ្ឈប់រាល់ទម្រង់នៃការចូលជ្រៀតជ្រែក និងការតាមឃ្លាំមើលការនិយាយតាមបណ្តាញសង្គម និងតាមអនឡាញ (ហ្វាំងឡង់)។
៨០. ចាត់វិធានការចាំបាច់នានា ដើម្បីអនុញ្ញាតឱ្យសមាជិកសមាជិកាបក្សប្រឆាំងចូលរួមក្នុងជីវិតនយោបាយកម្ពុជាឡើងវិញ (បារាំង)។
៨១. ធានានូវសេរីភាពក្នុងការបញ្ចេញមតិសម្រាប់ពលរដ្ឋ និងអ្នកសារព័ត៌មានទាំងអស់ រួមទាំង តាមអ៊ីនធឺណិត ដោយធ្វើការកែលម្អការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញលើកចុងក្រោយ ក៏ដូចជា ប្រកាសអន្តរក្រសួងកាលពីខែឧសភា ឆ្នាំ២០១៨ ដែលបានអនុញ្ញាតឱ្យមានការតាមឃ្លាំមើលមាតិកា/ខ្លឹមសារអត្ថបទតាមអ៊ីនធឺណិត (បារាំង)។
៨២. ធ្វើឱ្យក្រមព្រហ្មទណ្ឌស្របទៅនឹងមាត្រា១៩ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ តាមរយៈការលុបចោល ឬការធ្វើវិសោធនកម្មមាត្រាទាំងឡាយ ដែលចែងអំពីបទប្រមាថព្រះមហាក្សត្រ បទបរិហារកេរ្តិ៍ បទប្រមាថញុះញង់ ការបង្ខិតបង្ខំដោយខុសច្បាប់របស់អាជ្ញាធរតុលាការ និងការបដិសេធសេចក្តីសម្រេចរបស់តុលាការ (អាល្លឺម៉ង់)។
៨៣. ធានាសេរីភាពក្នុងការបញ្ចេញមតិតាមអ៊ីនធឺណិត ដោយការលុបចោលសេចក្តីប្រកាសអន្តរក្រសួង(លេខ១៧០) ស្តីពីការត្រួតពិនិត្យការបោះពុម្ពផ្សាយរបស់គេហទំព័រ និងដំណើរការប្រព័ន្ធផ្សព្វផ្សាយសង្គមតាមអ៊ីនធឺណិត(អាល្លឺម៉ង់)។

៨៤. លុបចោលបទប្បញ្ញត្តិនានានៃក្រមព្រហ្មទណ្ឌ ដែលអាចត្រូវបានប្រើក្នុងការរឹត្បិតសេរីភាពក្នុងការបញ្ចេញមតិ ការជួប ប្រជុំ និងការបង្កើតសមាគម ព្រមទាំងការដកទោសព្រហ្មទណ្ឌទៅលើបទល្មើសផ្សេងៗ ដូចជា បទបរិហារកេរ្តិ៍ (អ៊ីស្លង់)។

៨៥. ចាត់វាល់វិធានការក្នុងការការពារ និងគាំទ្រដល់អ្នកសារព័ត៌មាន អ្នកការពារសិទ្ធិមនុស្ស កម្មករសហជីព សកម្មជនដីធ្លីនិងបរិស្ថាន និងតួអង្គសង្គមស៊ីវិលដទៃទៀត ព្រមទាំងសមាជិកសមាជិកាគណបក្សប្រឆាំង(អ៊ីស្លង់)។

៨៦. អនុម័តវិធានការនានា ដែលមានគោលបំណងក្នុងការធានានូវសេរីភាពក្នុងការបញ្ចេញមតិ និងការទទួលបានសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយរបស់ប្រជាជនខ្លួន (កូឡុំប៊ី)។

៨៧. បង្កើតលក្ខខណ្ឌចាំបាច់ផ្សេងៗ ដើម្បីអនុញ្ញាតឱ្យបុគ្គលគ្រប់រូបទទួលបាននូវសិទ្ធិជាមូលដ្ឋាន ជាពិសេស សេរីភាពក្នុងការ បញ្ចេញមតិ ការបង្កើតសមាគម និងការជួបប្រជុំដោយសន្តិវិធី (កូស្តារីកា)។

៨៨. ស្តារឡើងវិញនូវលំហប្រជាធិបតេយ្យ និងនយោបាយ ដោយធានានូវការចូលរួមសម្រាប់គណបក្សនយោបាយផ្សេងៗ សង្គមស៊ីវិល និងប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ(ន័រវែស)។

៨៩. ដោះលែងភ្លាមៗពីការឃុំឃាំងបុគ្គលទាំងឡាយណា ដែលត្រូវបានឃុំខ្លួនដោយសារការអនុវត្តសេរីភាពក្នុងការបញ្ចេញមតិ និងការជួបប្រជុំដោយសន្តិវិធី ព្រមទាំងទម្លាក់ចោលរាល់ការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌប្រឆាំងនឹងបុគ្គលទាំងនេះ (ន័រវែស)។

៩០. បន្តបង្កើនប្រើប្រាស់កិច្ចខិតខំប្រឹងប្រែងដែលមានស្រាប់ ដើម្បីធ្វើឱ្យលំហប្រជាធិបតេយ្យកាន់តែប្រកបដោយបរិយាប័ន្ន (សាធារណរដ្ឋកូរ៉េ)។

៩១. បង្កើតលក្ខខណ្ឌផ្សេងៗ ដែលអំណោយផលដល់ការតស៊ូមតិ និងការប្រកួតប្រជែងនយោបាយដោយសេរី ដើម្បីកសាងឡើងវិញលទ្ធិប្រជាធិបតេយ្យមួយ ដែលក្នុងនោះប្រព័ន្ធផ្សព្វផ្សាយ និងសង្គមស៊ីវិល រួមទាំងអ្នកការពារសិទ្ធិមនុស្សអាចបំពេញការងាររបស់ពួកគេដោយគ្មានការជ្រៀតជ្រែក ឬរារាំង ដូចដែលបានផ្តល់អនុសាសន៍ដោយប្រទេសអ៊ីស្លង់កាលពីជុំកន្លងមក ហើយជាពិសេស ដើម្បីធានាថា ការងាររបស់ពួកគេមិនត្រូវបានរារាំងតាមរយៈការរឹតត្បិតទៅលើសេរីភាពក្នុងការប្រជុំ ឬការបញ្ចេញមតិ មិនថានៅក្នុង ឬនៅក្រៅបណ្តាញអ៊ីនធឺណិតឡើយ(អ៊ីស្លង់)។

៩២. កែទម្រង់ក្រមព្រហ្មទណ្ឌ ដើម្បីធានាថា សេរីភាពក្នុងការបញ្ចេញមតិ ការជួបប្រជុំ និងការបង្កើតសមាគម ត្រូវបានធានាបន្ថែមទៅលើការការពារសិទ្ធិអ្នកការពារសិទ្ធិមនុស្ស និងដើម្បីធានាថា អ្នកទាំងនេះអាចបំពេញការងាររបស់ពួកគេដោយគ្មានការភ័យខ្លាចពីការបំភិតបំភ័យ(អេស្ប៉ាញ)។

៩៣. ការពារសិទ្ធិអ្នកការពារសិទ្ធិមនុស្ស និងធ្វើឱ្យច្បាប់ បទប្បញ្ញត្តិ និងគោលនយោបាយនានា ស្តីពីសេរីភាពក្នុងការបញ្ចេញមតិ ការបង្កើតសមាគម និងការជួបប្រជុំ ស្របជាមួយនឹងកាតព្វកិច្ចអន្តរជាតិ(អ៊ីតាលី)។

៩៤. កែសម្រួលការអនុម័ត និងការកែសម្រួលបទប្បញ្ញត្តិថ្មីៗនេះ ដែលរំលោភលើសេរីភាពក្នុងការបញ្ចេញមតិ និងការបង្កើតសមាគម រួមទាំង ហេតុផលមិនច្បាស់លាស់និងទូលំទូលាយ សម្រាប់ការរារាំង ការបោះពុម្ពផ្សាយនៅលើអ៊ីនធឺណិត នៅក្នុងប្រកាសស្តីពីការត្រួតពិនិត្យការបោះពុម្ពផ្សាយរបស់គេហទំព័រ និងប្រព័ន្ធផ្សព្វផ្សាយសង្គម (ស៊ុយអែត)។

៩៥. ធានាថា ពលរដ្ឋទាំងអស់អាចទទួលបានយ៉ាងពេញលេញនូវសិទ្ធិរបស់ពួកគេ ក្នុងការបញ្ចេញមតិ និងការជួបប្រជុំ ហើយនិងការបង្កើតសមាគមដោយសន្តិវិធី (ស្វ៊ីស)។

៩៦. ធ្វើវិសោធនកម្មច្បាប់ស្តីពីទូរគមនាគមន៍ និងអនុម័តច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានស្របទៅតាមបទដ្ឋានអន្តរជាតិនៃសេរីភាពបញ្ចេញមតិ និងសិទ្ធិជីវិតឯកជន(ស្វ៊ីស)។

៩៧. លុបចោលការបិទប្រព័ន្ធផ្សព្វផ្សាយដោយបង្ខំ និងលុបចោលបទប្បញ្ញត្តិនានានៃក្រមព្រហ្មទណ្ឌ ដែលដាក់ទោសព្រហ្មទណ្ឌលើបទបរិហារកេរ្តិ៍ និងរឹតត្បិតសេរីភាពក្នុងការបញ្ចេញមតិ និងការប្រជុំ ព្រមទាំងលុបចោលដោយគ្មានលក្ខខណ្ឌនូវការហាមឃាត់សមាជិកសមាជិកាអតីតគណបក្សសង្គ្រោះជាតិចំនួន១១៨ រូប ពីការចូលរួមក្នុងសកម្មភាពនយោបាយ (ចក្រភពអង់គ្លេស និងអៀរឡង់ខាងជើង)។
៩៨. លុបចោលភ្លាមៗរាល់ការរឹតត្បិតដែលមិនសមស្រប ទៅលើសង្គមស៊ីវិល និងប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ រួមទាំងដកចេញនូវសេចក្តីសម្រេចអន្តរក្រសួង គឺប្រកាសលេខ១៧០ ស្តីពីការសម្តែងមតិតាមប្រព័ន្ធឌីជីថល (សហរដ្ឋអាមេរិក)។
៩៩. ចាត់រាល់វិធានការចាំបាច់ ដើម្បីធានាឱ្យមានបរិយាកាសមួយដែលមានសុវត្ថិភាពធានាដល់ការទទួលបានពេញលេញនូវសេរីភាពបញ្ចេញមតិរបស់អ្នកសារព័ត៌មាន និងប្រជាជនទូទៅ ព្រមទាំងស៊ើបអង្កេតនិងដាក់ទោសទណ្ឌគ្រប់រូបភាពនៃអំពើហិង្សាប្រឆាំងពួកគេ(អាហ្សង់ទីន)។
១០០. ពិចារណាលុបចោលច្បាប់ ដែលអនុញ្ញាតឱ្យរំលាយគណបក្សនយោបាយ និងការហាមប្រាមអ្នកដឹកនាំនយោបាយដោយគ្មានដំណើរការតាមនីតិត្រឹមត្រូវ (ប្រេស៊ីល)។
១០១. ចាត់វិធានការដើម្បីការពារសេរីភាពក្នុងការបញ្ចេញមតិ តាមក្នុង និងក្រៅប្រព័ន្ធអ៊ីនធឺណិត ក៏ដូចជាសេរីភាពខាងសមាគម និងការជួបប្រជុំ (ប្រេស៊ីល)។
១០២. ពង្រឹងការចូលរួមបែបប្រជាធិបតេយ្យ តាមរយៈការធានាឯករាជ្យភាពនៃប្រព័ន្ធផ្សព្វផ្សាយដោយបង្កើតបរិយាកាសដែលមានសុវត្ថិភាពនិងអំណោយផលសម្រាប់សង្គមស៊ីវិល និងសហជីព ព្រមទាំងធ្វើការជំរុញឱ្យមានការចូលរួមដោយពេញលេញរបស់គណបក្សប្រឆាំងក្នុងការបោះឆ្នោតឃុំ/សង្កាត់ ព្រឹទ្ធសភា និងរដ្ឋសភានៅអាណត្តិក្រោយ (កាណាដា)។
១០៣. លើកកម្ពស់កិច្ចសន្ទនាក្នុងចំណោមតួអង្គនយោបាយ អំពីសេរីភាព និងសិទ្ធិរបស់ប្រជាជន ព្រមទាំងដំណើរការប្រជាធិបតេយ្យ ក្នុងគោលបំណងដើម្បីបង្រួបបង្រួមប្រជាជនឆ្ពោះទៅរកការអភិវឌ្ឍ។ នៅក្នុងដំណើរការនេះ ត្រូវធានាឱ្យបាននូវបរិយាកាស ដែលសិទ្ធិរបស់តួអង្គនយោបាយទាំងអស់ សង្គមស៊ីវិល ប្រព័ន្ធផ្សព្វផ្សាយ និងតួអង្គផ្សេងទៀតត្រូវបានគោរព ហើយសកម្មភាពរបស់ពួកគេមិនត្រូវបានរឹតត្បិត (ជប៉ុន)។
១០៤. បង្កើតគណបក្សប្រឆាំងឡើងវិញ គឺគណបក្សសង្គ្រោះជាតិ និងដាក់សមាជិកសមាជិកាគណបក្សនេះនៅកន្លែងដើមវិញ(កាណាដា)។
១០៥. ធ្វើឱ្យច្បាប់ បទប្បញ្ញត្តិ និងគោលនយោបាយនានាស្តីពីសេរីភាពក្នុងការបញ្ចេញមតិ សេរីភាពក្នុងការបង្កើតសមាគម និងសេរីភាពក្នុងការជួបប្រជុំជាសាធារណៈ ស្របទៅតាមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ដាណឺម៉ាក)។
១០៦. ខិតខំប្រឹងប្រែងទ្វេដង ដើម្បីការពារសេរីភាពនៃគំនិត និងការបញ្ចេញមតិទាំងក្នុង និងការក្រៅប្រព័ន្ធអ៊ិជីណែតដើម្បីធានា និងលើកកម្ពស់បរិយាកាសមួយប្រកបដោយសុវត្ថិភាពសម្រាប់អ្នកសារព័ត៌មាន អ្នកការពារសិទ្ធិមនុស្ស និងគណបក្សប្រឆាំង ព្រមទាំងស៊ើបអង្កេតយ៉ាងមានប្រសិទ្ធភាព និងយ៉ាងហ្មត់ចត់ទៅលើករណីវាយប្រហារប្រឆាំងអ្នកទាំងនោះ (លីទុយអានី)។
១០៧. ចាត់វិធានការចាំបាច់នានា ដើម្បីធានាថា សិទ្ធិសេរីភាពក្នុងការប្រមូលផ្តុំ និងសមាគម មិនត្រូវបានរារាំងដោយការរឹតត្បិតតាមទំនើងចិត្ត និង/ឬការប្រើប្រាស់កម្លាំងលើសលុប(លីទុយអានី)។
១០៨. លុបចោលលក្ខខណ្ឌតម្រូវខាងការចុះបញ្ជីសហជីពនិងការរបាយការណ៍ដែលនាំឱ្យមានការរឹតត្បិតដល់សេរីភាពក្នុងការបង្កើតសមាគម ការជួបប្រជុំ និងការបញ្ចេញមតិ (ក្រិក)។
១០៩. បញ្ឈប់រាល់ការបៀតបៀន និងជ្រៀតជ្រែកដោយបំពានលើគណបក្សប្រឆាំង អ្នកការពារសិទ្ធិមនុស្ស និងសកម្មជនការងារ ព្រមទាំងធ្វើវិសោធនកម្មច្បាប់ និងបទប្បញ្ញត្តិនានា ដែលត្រូវបានប្រើប្រាស់យ៉ាងមាន ប្រសិទ្ធភាព

ដើម្បីកំណត់ព្រំដែននៃសេរីភាពក្នុងការបង្កើតសមាគម និងការជួបប្រជុំ ដូចជា បទប្បញ្ញត្តិជាក់លាក់មួយចំនួននៅក្នុងច្បាប់ស្តីពីគណបក្ស នយោបាយ ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងច្បាប់ស្តីពីសហជីព (ហ្វាំងឡង់)។

១១០. ធានាឱ្យមានលំហសេរីភាពមួយ ដែលអនុញ្ញាតឱ្យក្រុមអ្នកការពារសិទ្ធិមនុស្ស និងអ្នកសារព័ត៌មានសម្តែងមតិរបស់ខ្លួន ដោយសេរីទាំងនៅក្នុង និងនៅក្រៅប្រព័ន្ធអ៊ីនធឺណិត ដោយគ្មានការភ័យខ្លាចពីការយាយីឬការសងសឹក និង បញ្ឈប់ការផ្តន្ទាទោសចំពោះការអនុវត្តសិទ្ធិជាមូលដ្ឋានរបស់ពួកគេ ដោយក្រមព្រហ្មទណ្ឌ និងច្បាប់ស្តីពីទូរគមនាគមន៍ (ហូឡង់)។

១១១. ដោះលែងអ្នកទោសនយោបាយ និងក្រុមអ្នកប្រឆាំង ដែលនៅសេសសល់ជាបន្ទាន់ និងដោយគ្មានលក្ខខណ្ឌ និងទម្លាក់ចោលនូវការចោទប្រកាន់ទាំងអស់ប្រឆាំងនឹងពួកគេ រួមទាំងការដោះលែងលោក កឹម សុខា មេដឹកនាំគណបក្សប្រឆាំង ឱ្យមានសេរីភាពពេញលេញឡើងវិញ(នូវែលសេឡង់)។

១១២. បញ្ចប់ការយាយី និងការចាប់ខ្លួនដោយបំពាន ទៅលើអ្នកការពារសិទ្ធិមនុស្ស សមាជិកសមាជិកាគណបក្សប្រឆាំង សកម្មជននានា និងអ្នកសារព័ត៌មាន(ក្រូអាស៊ី)។

១១៣. ការពារពីការយាយី ការចាប់ខ្លួនដោយបំពាន និងការវាយប្រហារលើរូប កាយប្រឆាំងនឹងអ្នកសារព័ត៌មាន អ្នកការពារសិទ្ធិមនុស្ស សមាជិកសមាជិកាគណបក្សប្រឆាំង និងកម្មករសហជីព ព្រមទាំងស៊ើបអង្កេត និងផ្តន្ទាទោសអ្នកប្រព្រឹត្តអំពើវាយប្រហារបែបនេះ(ស្លូវេនី)។

១១៤. បង្កើនកិច្ចខិតខំប្រឹងប្រែងក្នុងការបង្ការការយាយីចំពោះអ្នកការពារសិទ្ធិមនុស្ស អ្នកសារព័ត៌មាន កម្មករសហជីព អ្នកតវ៉ា ឬបាតុករ តួអង្គដីធ្លី និងតួអង្គសង្គមស៊ីវិលដទៃ ទៀត ព្រមទាំងការពារសិទ្ធិរបស់ពួកគេ (សាធារណរដ្ឋឆេក)។

១១៥. អនុម័តនូវវិធានការចាំបាច់នានា ដើម្បីធានាការពារសិទ្ធិរបស់អ្នកទាំងឡាយដែលធ្វើការដើម្បីការពារ និងលើកកម្ពស់ សិទ្ធិមនុស្ស ជាពិសេសអ្នកការពារសិទ្ធិមនុស្ស ដោយធ្វើការស៊ើបអង្កេតនិងផ្តន្ទាទោសអ្នកដែលទទួលខុសត្រូវចំពោះការគំរាមកំហែង និងប្រើអំពើហិង្សាលើពួកគេ និងគ្រួសាររបស់ពួកគេ (អាហ្សង់ទីន)។

១១៦.អនុម័តនូវវិធានការចាំបាច់នានា ដើម្បីការពារសិទ្ធិអ្នកការពារសិទ្ធិមនុស្ស កម្មករសហជីព និងអ្នកសារព័ត៌មាន (ស៊ីលី)។

១១៧. បង្កើតបរិយាកាសអំណោយផលមួយសម្រាប់សេរីភាព និងពហុភាពនៃប្រព័ន្ធផ្សព្វផ្សាយ រួមមានបញ្ឈប់ការយាយីតាមផ្លូវតុលាការប្រឆាំងនឹងអ្នកសារព័ត៌មាន និងការយកករណីរំលោភលើច្បាប់ពន្ធដារ ដើម្បីយាយីដល់ប្រព័ន្ធផ្សព្វផ្សាយ និងសមាគមផ្សេងៗ(ក្រិក)។

១១៨. បន្តអនុវត្តវិធានការនានា ដើម្បីពង្រឹងឯករាជ្យភាពទាំងប្រព័ន្ធតុលាកា និងប្រព័ន្ធផ្សព្វផ្សាយ(អ៊ីតាលី)។

១១៩. បញ្ឈប់ឥទ្ធិពលដ៏លើសលុបនៃអង្គនីតិប្រតិបត្តិ ដែលជះឥទ្ធិពលដល់ការងាររបស់ចៅក្រម និងព្រះរាជអាជ្ញា ដោយការធ្វើវិសោធនកម្មច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រមនិងព្រះរាជអាជ្ញា និងច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម(អាល្លឺម៉ង់)។

១២០. បង្កើតសាលាឧទ្ធរណ៍តំបន់ស្របទៅតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងធានាដល់ដំណើរការដ៏សមស្របរបស់តុលាការនេះនៅត្រឹមឆ្នាំ២០២៣(ក្រិក)។

១២១. បញ្ចប់ដំណើរការកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ដោយការការពារឯករាជ្យភាពនិងភាពមិនលំអៀងនៃប្រព័ន្ធតុលាការ មន្ត្រីតុលាការ និងចៅក្រមឱ្យស្របទៅតាមបទដ្ឋានអន្តរជាតិ(ន័រវែស)។

១២២. ចាត់វាល់វិធានការចាំបាច់នានា ដើម្បីពង្រឹងនីតិរដ្ឋ និងធានានូវឯករាជ្យភាពពេញលេញរបស់តុលាការ ដែលមានសង្គតិភាពជាមួយនឹងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ(លីទុយអានី)។

១២៣. ប្រកាន់ខ្ជាប់នូវបទដ្ឋានអន្តរជាតិស្តីពីឯករាជ្យភាពស្ថាប័ន ដូចជា តុលាការ និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដើម្បីធានាថា ដំណើរការបោះឆ្នោតមានលក្ខណៈសេរី ត្រឹមត្រូវ និងមានតម្លាភាព (អៀរឡង់)។
១២៤. បន្តកំណែទម្រង់ប្រព័ន្ធយុត្តិធម៌បន្ថែមទៀត និងបង្កើតប្រព័ន្ធតុលាការឯករាជ្យមួយ ដែលត្រូវបានប្រជាជនជឿជាក់ និងប្រើប្រាស់។ ដើម្បីធ្វើឱ្យសម្រេចបានលើចំណុចនេះ ត្រូវប្រើប្រាស់ជាអតិបរិមានូវគំរូរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ជប៉ុន)។
១២៥. ពង្រឹងភាពឯករាជ្យ និងការប្រព្រឹត្តទៅរបស់តុលាការ ជាពិសេសតាមរយៈការលុបចោល ឬការធ្វើវិសោធនកម្មយ៉ាងចាំបាច់នូវច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រមនិងព្រះរាជអាជ្ញា និងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម(អូទ្រីស)។
១២៦. ចាត់វាល់វិធានការចាំបាច់នានា ដើម្បីកាត់បន្ថយរយៈពេល ដែលបុគ្គលម្នាក់ៗត្រូវចំណាយនៅក្នុងការឃុំខ្លួនបណ្តោះអាសន្ន (អូទ្រីស)។
១២៧. ធ្វើវិសោធនកម្មច្បាប់ស្តីពីការរៀបចំអង្គការតុលាការ លក្ខន្តិកៈចៅក្រមនិងព្រះរាជអាជ្ញា ព្រមទាំងការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដើម្បីធានា និងការពារឯករាជ្យភាពរបស់តុលាការ (បែលហ្ស៊ិក)។
១២៨. បន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ក្នុងការលើកកម្ពស់ និងការពារសិទ្ធិមនុស្សតាមរយៈការប្តេជ្ញាចិត្តដ៏មុតមាំចំពោះអភិបាលកិច្ចល្អ តម្លាភាព ការចូលរួមរបស់សាធារណជននៅក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្ត និងការទទួលបានយុត្តិធម៌(តួកគី)។
១២៩. ចាត់វិធានការបន្ថែមទៀត ដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ តាមរយៈការពង្រឹងគណនេយ្យភាព និងសមត្ថភាពស្ថាប័ន (ប៊ូតង់)។
១៣០. បង្កើនកិច្ចខិតខំប្រឹងប្រែងលើបញ្ហាដីធ្លី រួមមាន តាមរយៈការអនុវត្តប្រកបដោយប្រសិទ្ធភាព និងតម្លាភាពនូវវិធានការនានា ដើម្បីដោះស្រាយការបណ្តេញចេញ និងផ្តល់សំណងដោយយុត្តិធម៌ដល់ជនរងគ្រោះនៃការរំលោភយកដីធ្លី ជាពិសេសជនជាតិដើមភាគតិច(អ៊ីតាលី)។
១៣១. ធានាថា ជនរងគ្រោះពីការដណ្តើមយកដីធ្លី ត្រូវ ទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ ទទួលបានសំណងសមរម្យ និងដោយគ្មានការរើសអើងចំពោះការទទួលបានយុត្តិធម៌នៅពេលសមស្របណាមួយ(ស្វ៊ីស)។
១៣២. ជម្នះរាល់ឧបសគ្គនានា ដើម្បីទទួលបានយុត្តិធម៌សម្រាប់ស្ត្រីជនរងគ្រោះដោយអំពើហិង្សា(អ៊ីរ៉ាក់)។
១៣៣. ធានាឱ្យបាននូវគណនេយ្យភាពចំពោះការរំលោភបំពានសិទ្ធិមនុស្ស តាមរយៈការស៊ើបអង្កេតឯករាជ្យ និងការផ្តន្ទាទោសជនល្មើស (អ៊ុយក្រែន)។
១៣៤. អនុវត្តយន្តការជួសជុលមួយ សម្រាប់ជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍(ស្វ៊ីស)។
១៣៥. ពង្រឹងកិច្ចខិតខំប្រឹងប្រែង ដើម្បីធានាការចុះបញ្ជីកំណើតឱ្យមនុស្សគ្រប់រូប ដែលកើតនៅក្នុងប្រទេសកម្ពុជា រួមទាំងជនជាតិភាគតិច និងប្រជាជន ដែលពិបាកទទួលបានសេវានេះ ដូចជា សហគមន៍តាមព្រំដែន(ម៉ិកស៊ិក)។
១៣៦. អនុម័តរាល់វិធានការចាំបាច់ ដើម្បីធានាថា អ្នកដែលកើតនៅក្នុងប្រទេសកម្ពុជាអាចទទួលបានសញ្ជាតិខ្មែរ ហើយពួកគេអាចទទួលបានលិខិតបញ្ជាក់អត្តសញ្ញាណ(អេស្ប៉ាញ)។
១៣៧. បង្កើតលក្ខខណ្ឌនានាសម្រាប់ប្រជាធិបតេយ្យពហុបក្សពិតប្រាកដនៅក្នុងប្រទេស និងសម្រាប់ការប្រព្រឹត្តទៅនៃការបោះឆ្នោតដោយសេរី និងយុត្តិធម៌(ក្រិក)។
១៣៨. បន្តកិច្ចប្រឹងប្រែងរបស់ខ្លួន ក្នុងវិស័យកំណែទម្រង់ការបោះឆ្នោត(ប៊ូតង់)។
១៣៩. បន្តការងារ ដើម្បីរក្សាដំណើរការបោះឆ្នោតបែបពហុបក្ស(ស៊ីលី)។

១៤០. ចាត់វិធានការនានា ដើម្បីលើកកម្ពស់លទ្ធភាពទទួលបានសេវាអប់រំ និងថែទាំសុខភាពដោយឥតបង់ថ្លៃ ជាពិសេសនៅតំបន់ជនបទ(ប៉ាគីស្ថាន)។
១៤១. បង្កើនកិច្ចខិតខំប្រឹងប្រែង ដើម្បីធានានូវសិទ្ធិសង្គមកិច្ច និងសេដ្ឋកិច្ចរបស់ពលរដ្ឋទូទាំងប្រទេស(សហព័ន្ធរុស្ស៊ី)។
១៤២. អនុវត្តសកម្មភាពនានា ដើម្បីបន្តលើកកម្ពស់គុណភាព និងលទ្ធភាពទទួលបានសេវាថែទាំសុខភាព និងអប់រំប្រកបដោយសមធម៌ (គុយបា)។
១៤៣. ចាត់វិធានការបន្ថែមទៀត ដើម្បីកាត់បន្ថយគម្លាតនៃការអភិវឌ្ឍ ក៏ដូចជាការបង្កើនលទ្ធភាពទទួលបានសេវាអប់រំ និងថែទាំសុខភាព ជាពិសេសសម្រាប់ប្រជាជននៅតាមតំបន់ជនបទ ដើម្បីធានាថា គ្មាននរណាម្នាក់ត្រូវបានគេទុកចោលឡើយ (ថៃ)។
១៤៤. បន្តកិច្ចខិតខំប្រឹងប្រែងសំដៅលើកកម្ពស់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច ព្រមទាំងធ្វើឱ្យការអប់រំអាចទទួលបានសម្រាប់ពលរដ្ឋទាំងអស់(អេហ្ស៊ីប)។
១៤៥. ចាត់វិធានការបន្ថែមទៀត ដើម្បីផ្តល់លទ្ធភាពទទួលបានការអប់រំសម្រាប់ទាំងអស់គ្នា ដោយការបង្កើនសេវាអប់រំប្រកបដោយសមធម៌ ដល់កុមារនិងយុវជនទាំងអស់ ទាំងការអប់រំក្នុងប្រព័ន្ធនិងក្រៅប្រព័ន្ធ(ឥណ្ឌូណេស៊ី)។
១៤៦. បន្តធ្វើឱ្យប្រសើរឡើងនូវគុណភាព និងប្រសិទ្ធភាពនៃសេវាអប់រំនៅគ្រប់សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទូទៅទាំងអស់ (សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ)។
១៤៧. បន្តវិធានការនានា ដែលពង្រីកដល់វិស័យសង្គម និងថែទាំសុខភាព (ស៊ែប៊ី)។
១៤៨. ការពារសិទ្ធិរបស់កសិករ និងអ្នកផ្សេងទៀត ដែលកំពុងធ្វើការនៅតាមតំបន់ជនបទ រួមទាំងតាមរយៈការធានាថា ពួកគេត្រូវបានផ្តល់ឱ្យនូវសំណងសមរម្យក្នុងករណីការតាំងលំនៅថ្មី (ព័រទុយហ្គាល់)។
១៤៩. អនុម័តវិធានការនានា ដើម្បីទប់ស្កាត់ការបណ្តេញប្រជាជនកម្ពុជាចេញពីដីរបស់ខ្លួនដោយខុសច្បាប់ និងប្រើប្រាស់យន្តការផ្អែកលើគណនេយ្យភាព និងតម្លាភាព ដើម្បីដោះស្រាយវិវាទដីធ្លីប្រកបដោយសមភាព និងឆាប់រហ័ស ដូចដែលបានជំរុញដោយក្រុមប្រឹក្សាសិទ្ធិមនុស្ស នៅក្នុងសេចក្តីសម្រេចលេខ៣៦/៣២ របស់ខ្លួន ដែលបានអនុម័តជាឯកច្ឆន្ទ (កាណាដា)។
១៥០. បន្តការផ្តួចផ្តើមជាវិជ្ជមាន ដើម្បីសម្របសម្រួលការផ្គត់ផ្គង់ទឹកស្អាតដល់ប្រជាពលរដ្ឋក្រីក្រ (បូលីវី)។
១៥១. ធានាថា សិទ្ធិសហជីពរបស់កម្មករ ត្រូវបានធានាការពារស្របតាមអនុសញ្ញាអង្គការពលកម្មអន្តរជាតិ ហើយសហជីព អាចចុះបញ្ជីដោយគ្មានការរារាំង និងជាតំណាងឱ្យសមាជិកទាំងអស់របស់ពួកគេ (ស៊ុយអែត)។
១៥២. ដូចដែលរដ្ឋាភិបាល បានប្តេជ្ញាចិត្តបន្ទាប់ពីការពិនិត្យមើលក្នុងដំណើរការពិនិត្យជាសកលតាមកាលកំណត់ជុំទី២ របស់កម្ពុជា ចូរធ្វើឱ្យមានភាពងាយស្រួល និងកែទម្រង់នីតិវិធីចុះបញ្ជីសម្រាប់សហជីព និងអង្គការសង្គមស៊ីវិលដទៃទៀត (សហរដ្ឋអាមេរិក)។
១៥៣. ធ្វើវិសោធនកម្មច្បាប់ស្តីពីសហជីព ដោយធ្វើការពិគ្រោះយោបល់ជាមួយកម្មករ អ្នកតស៊ូមតិខាងការងារ និងភាគីដទៃទៀត ដើម្បីឱ្យច្បាប់នេះស្របទៅតាមអនុសញ្ញាអង្គការពលកម្មអន្តរជាតិលេខ៨៧ និង៩៨ (បែលហ្ស៊ិក)។
១៥៤. បន្តគោលនយោបាយ និងកម្មវិធីដែលកំពុងអនុវត្ត ដើម្បីធានានូវការថែទាំសុខភាពប្រកដោយគុណភាពសម្រាប់ទាំងអស់គ្នា(ឥណ្ឌា)។
១៥៥. បន្តផែនការយុទ្ធសាស្ត្រសុខាភិបាលឆ្នាំ២០១៦-២០២០ របស់ក្រសួងសុខាភិបាល ដើម្បីធានាថា ប្រជាពលរដ្ឋទទួលបានសេវាថែទាំសុខភាពពេញលេញ(មីយ៉ាន់ម៉ា)។
១៥៦. អនុម័តអភិក្រមសុខាភិបាលសាធារណៈ និងសិទ្ធិមនុស្ស ចំពោះបញ្ហាគ្រឿងញៀននៅលើពិភពលោក រួមទាំង បញ្ឈប់ការដាក់ទោសព្រហ្មទណ្ឌចំពោះការប្រើប្រាស់គ្រឿងញៀន ព្រមទាំងធ្វើការផ្តល់សេវាកាត់បន្ថយគ្រោះថ្នាក់ (ព័រទុយហ្គាល់)។

១៥៧. បន្តការវិនិយោគលើការកែលំអហេដ្ឋារចនាសម្ព័ន្ធសុខាភិបាលសាធារណៈ ជាពិសេសនៅតំបន់ជនបទ ដើម្បីធានាឱ្យមានការអនុវត្តផែនការយុទ្ធសាស្ត្រសុខាភិបាលឆ្នាំ២០១៦-២០២០ ប្រកបដោយប្រសិទ្ធភាព (សិង្ហបុរី)។
១៥៨. បន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីលើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធការថែទាំសុខភាពជារួម និងបង្កលក្ខណៈងាយស្រួលក្នុងការទទួលបានប្រព័ន្ធសុខាភិបាលសាធារណៈ និងសេវាមាតុភាពសម្រាប់ស្ត្រីជាពិសេស (អៀរឡង់)។
១៥៩. គាំទ្រដល់កិច្ចខិតខំប្រឹងប្រែង ដើម្បីទប់ស្កាត់ជំងឺរបេង ហើយគោលនយោបាយពាក់ព័ន្ធនានា ដែលមានគោលបំណងលុបបំបាត់ជំងឺរបេងទាំងស្រុង ត្រូវបានអនុវត្តយ៉ាងពេញលេញ(ម៉ាឡេស៊ី)។
១៦០. អនុវត្តគោលយ៉ាងពេញលេញនូវនយោបាយ និងចែករំលែកការអនុវត្តល្អៗក្នុងការប្រយុទ្ធប្រឆាំងជំងឺរបេង និងមេរោគហ៊ីវ/ អេដស៍ (សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ)។
១៦១. បន្តអភិវឌ្ឍយ៉ាងខ្លាំងក្លាលើវិស័យអប់រំ ដើម្បីធានាឱ្យបានកាន់តែប្រសើរឡើងនូវសិទ្ធិទទួលបានការអប់រំរបស់ប្រជាជន (ចិន)។
១៦២. បន្តវិធានការដែលកំពុងអនុវត្ត ដើម្បីលើកកម្ពស់ការអប់រំសម្រាប់ទាំងអស់គ្នា(ឥណ្ឌា)។
១៦៣. បន្តការអនុវត្តច្បាប់ពាក់ព័ន្ធនានា ដើម្បីធានាថាប្រជាពលរដ្ឋទាំងអស់អាចទទួលបានការអប់រំដោយឥតបង់ថ្លៃនៅកម្រិតបឋមសិក្សា និងមធ្យមសិក្សានៃសាលារៀនសាធារណៈ ហើយប្រជាពលរដ្ឋទាំងអស់អាចទទួលបានការអប់រំយ៉ាងហោចណាស់ប្រាំបួនឆ្នាំ (មីយ៉ាន់ម៉ា)។
១៦៤. បន្តកិច្ចខិតខំប្រឹងប្រែង ដើម្បីធានានូវការផ្តល់សេវាអប់រំប្រកបដោយសមធម៌ដល់កុមារទាំងអស់ តាមរយៈការអប់រំទាំងក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ (ប៉ាគីស្ថាន)។
១៦៥. បន្តកិច្ចខិតខំប្រឹងប្រែង ដើម្បីធានានូវការអប់រំកម្រិតមូលដ្ឋានដោយឥតបង់ថ្លៃនិងជាសកល ជាមួយនឹងវិធានការនានាប្រកបដោយបរិយាប័ន្ន ជាពិសេសសម្រាប់ក្រុមងាយរងគ្រោះ(សាធារណរដ្ឋកូរ៉េ)។
១៦៦. បង្កើតធនធានមនុស្ស និងហិរញ្ញវត្ថុ ដើម្បីធានាការចុះឈ្មោះចូលរៀនសម្រាប់ទាំងអស់គ្នានៅកម្រិតបឋមសិក្សា និងមធ្យមសិក្សា(សេណេហ្កាល់)។
១៦៧. វិនិយោគលើការបណ្តុះបណ្តាលគ្រូបង្រៀន ដើម្បីធានាថា ជំនាញនិងចំណេះដឹងរបស់ពួកគេនៅតែទាន់សម័យ ដើម្បីបង្កើនគុណភាពនៃការបង្រៀនរបស់ពួកគេ(សិង្ហបុរី)។
១៦៨. បន្តខិតខំប្រឹងប្រែង ដើម្បីធានានូវសិទ្ធិទទួលបានការអប់រំកម្រិតបឋមសិក្សាប្រកបដោយបរិយាប័ន្ន ឥតបង់ថ្លៃ និងជាកាតព្វកិច្ច (ទុយនីស៊ី)។
១៦៩. បន្តការខិតខំប្រឹងប្រែង ដើម្បីធានានូវការអប់រំសម្រាប់ទាំងអស់គ្នាប្រកបដោយបរិយាប័ន្ន និងគុណភាពប្រកបដោយសមធម៌ (វៀតណាម)។
១៧០. បង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនបន្ថែមទៀត ដើម្បីលើកកម្ពស់គុណភាពនៃការអប់រំ និងលើកកម្ពស់កម្មវិធីដើម្បីទទួលបានការអប់រំសម្រាប់ទាំងអស់គ្នា ជាពិសេសការអប់រំនៅកម្រិតបឋមសិក្សា (សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ)។

១៧១. ពង្រីកកិច្ចប្រឹងប្រែង ដើម្បីលើកកម្ពស់សិទ្ធិមនុស្សសម្រាប់ស្ត្រី និងប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស អំពើហិង្សាក្នុងគ្រួសារ ព្រមទាំងអាជីវកម្មលើស្ត្រីនិងកុមារ(ន័រវែស)។
១៧២. លុបចោលការហាមឃាត់ដែលមានលក្ខណៈរើសអើង ចំពោះការរៀបការម្តងទៀតរបស់ស្ត្រីក្នុងរយៈពេល១២០ថ្ងៃបន្ទាប់ពីការលែងលះ ឬការប្រកាសទុកជាមោឃៈនៃការរៀបការ(អ៊ីស្លង់)។
១៧៣. បន្តយន្តការកំពុងអនុវត្ត សម្រាប់សមភាពយេនឌ័រ និងការផ្តល់សិទ្ធិអំណាចរបស់ស្ត្រី (ឥណ្ឌា)។

១៧៤. បន្តការអនុវត្តគោលនយោបាយសមភាពយេនឌ័រ ដើម្បីធានាការបញ្ជ្រាបយេនឌ័រទៅក្នុងវិស័យ និងកម្មវិធីទាំងអស់ (ប៉ាគីស្ថាន)។
១៧៥. បន្តពង្រឹងកម្មវិធីដោះស្រាយបញ្ហារើសអើងប្រឆាំងស្ត្រីនិងក្មេងស្រី និងលើកកម្ពស់សមភាពយេនឌ័រ(ហ្វីលីពីន)។
១៧៦. បន្តអនុវត្តគោលនយោបាយសមភាពយេនឌ័រ តាមរយៈការបញ្ជ្រាបយេនឌ័រទៅក្នុងវិស័យ និងកម្មវិធីទាំងអស់ (សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ #2)។
១៧៧. បង្កើនកិច្ចខិតខំប្រឹងប្រែងទ្វេដង ដើម្បីលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីក្នុងវិស័យច្បាប់ និងបញ្ចប់ការអនុវត្តដ៏គ្រោះថ្នាក់ និងផ្នត់គំនិតមានលក្ខណៈរើសអើង ដែលធ្វើឱ្យស្ត្រីកម្ពុជាក្លាយជាជនរងគ្រោះ(អ៊ុយរូហ្គាយ)។
១៧៨. បន្តអនុវត្តវិធានការនានា សំដៅលើកកម្ពស់សិទ្ធិស្ត្រី រួមទាំងការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងស្ត្រី (ម៉ាល់ឌីវ)។
១៧៩. ធានានូវកិច្ចខិតខំប្រឹងប្រែង ដើម្បីលុបបំបាត់រាល់ទម្រង់នៃអំពើហិង្សា និងការរើសអើងដោយហេតុផលយេនឌ័រ ព្រមទាំងធានានូវការផ្តល់អំណាចដល់ក្រុមងាយរងគ្រោះទាំងអស់ (នេប៉ាល់)។
១៨០. ពង្រឹងកិច្ចខិតខំប្រឹងប្រែង ដើម្បីការពារសិទ្ធិរបស់ក្រុមងាយរងគ្រោះបំផុត ដូចជា ស្ត្រី កុមារ និងជនមានពិការភាព ព្រមទាំងដើម្បីបង្ការ និងប្រយុទ្ធប្រឆាំងពលកម្មកុមារ និងអាជីវកម្មផ្លូវភេទ ក៏ដូចជាទម្រង់ដទៃៗទៀតនៃអំពើហិង្សា រួមទាំងអំពើហិង្សាក្នុងគ្រួសារផងដែរ (អ៊ីតាលី)។
១៨១. ពង្រឹងតួនាទីនិងឋានៈរបស់ស្ត្រី ព្រមទាំងលើកកម្ពស់និងការពារសិទ្ធិកុមារ និងសិទ្ធិជនមានពិការភាពក្នុងសង្គម (សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ)។
១៨២. ផ្តល់វគ្គបណ្តុះបណ្តាលជាកាតព្វកិច្ចស្តីពីនីតិវិធីផ្តន្ទាទោសលើករណីអំពើហិង្សាដោយហេតុផលយេនឌ័រ ដល់មន្ត្រីអនុវត្តច្បាប់ និងមន្ត្រីតុលាការ(សាធារណរដ្ឋម៉ុលដាវ៉ា)។
១៨៣. បែងចែកធនធានមនុស្ស និងហិរញ្ញវត្ថុឱ្យបានគ្រប់គ្រាន់ ដើម្បីបង្កើតមជ្ឈមណ្ឌលផ្តល់សេវាច្រកចេញចូលតែមួយឱ្យបានយ៉ាងតិច៥មណ្ឌល នៅត្រឹមឆ្នាំ២០២៤ សម្រាប់ផ្តល់សេវាកម្មគាំទ្រដោយឥតបង់ថ្លៃជូនជនរងគ្រោះនៃអំពើហិង្សាដោយហេតុផលយេនឌ័រ (អូស្ត្រាលី)។
១៨៤. ធ្វើការស៊ើបអង្កេតឱ្យបានទូលំទូលាយអំពីករណីអំពើហិង្សាក្នុងគ្រួសារ និងអំពើហិង្សាផ្លូវភេទ ព្រមទាំងធានាថាជនល្មើសត្រូវបានផ្តន្ទាទោស ហើយជនរងគ្រោះត្រូវទទួលបានសំណងសមរម្យ (សាធារណរដ្ឋម៉ុលដាវ៉ា)។
១៨៥. ធ្វើកំណែទម្រង់ច្បាប់ជាតិ ដើម្បីពង្រឹងការការពារស្ត្រីនិងកុមារ ប្រឆាំងអំពើហិង្សាក្នុងគ្រួសារ(សហព័ន្ធរុស្ស៊ី)។
១៨៦. ពង្រឹងយន្តការតុលាការ ដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើហិង្សាផ្លូវភេទ និងក្នុងគ្រួសារ និងការជួញដូរមនុស្ស ព្រមទាំងអនុវត្តកម្មវិធីលើកកម្ពស់ការយល់ដឹង និងការអប់រំអំពីបញ្ហាទាំងនេះ (តូហ្គោ)។
១៨៧. បង្កើតវិធានការដ៏រឹងមាំនានា សំដៅធានានូវការរក្សាក្មេងស្រីនៅក្នុងសាលារៀន (ដាណឺម៉ាក)។
១៨៨. ដាក់ទោសឧក្រិដ្ឋយ៉ាងជាក់លាក់ចំពោះការជ្រើសរើស និងប្រើប្រាស់ក្មេងអាយុក្រោម១៨ឆ្នាំ ចូលទៅក្នុងជម្លោះប្រដាប់អាវុធ និងក្រុមប្រដាប់អាវុធមិនមែនរដ្ឋ (ម៉ុងតេណេហ្គ្រោ)។
១៨៩. ចាត់វិធានការគ្រប់យ៉ាងដើម្បីការពារកុមារពីអាជីវកម្មផ្លូវភេទ ជាពិសេសនៅក្នុងបរិបទនៃ «ទេសចរកុមារកំព្រា» រួមទាំងតាមរយៈការពង្រឹងក្របខណ្ឌច្បាប់របស់ខ្លួន និងវិធានការបង្កើនការយល់ដឹង ព្រមទាំងដោយការធានាថា រាល់បទចោទប្រកាន់ទាំងអស់ត្រូវបានស៊ើបអង្កេត ជនរងគ្រោះត្រូវបានប៉ះប៉ូវ ហើយជនល្មើសត្រូវបានដាក់ទណ្ឌកម្ម (ព័រទុយហ្គាល់)។
១៩០. អនុវត្តអាយុស្របច្បាប់សម្រាប់អាពាហ៍ពិពាហ៍ ដើម្បីហាមឃាត់ការរៀបអាពាហ៍ពិពាហ៍កុមារ និងលើកកម្ពស់យុទ្ធនាការបង្កើនការយល់ដឹង ដើម្បីទប់ស្កាត់អាពាហ៍ពិពាហ៍កុមារ (ព័រទុយហ្គាល់)។

១៩១. ហាមឃាត់យ៉ាងស្របច្បាប់នូវការជួញដូរផ្លូវភេទកុមារ នៅក្នុងបរិបទនៃផែនការសកម្មភាពជាតិថ្មីសម្រាប់ការលុបបំបាត់ការជួញដូរនិងរត់ពន្ធមនុស្ស អាជីវកម្មលើកម្មករ និងអាជីវកម្មផ្លូវភេទដោយខុសច្បាប់ (អេស្ប៉ាញ)។
១៩២. បន្តពង្រឹងច្បាប់ និងយន្តការនានា ដែលហាមឃាត់រាល់ទម្រង់នៃការប្រព្រឹត្តមិនគប្បីលើកុមារ និងការពារពួកគេពីពលកម្មដោយបង្ខំ អាជីវកម្ម និងការរំលោភបំពានផ្លូវភេទ(ព្រុយណេដារ៉ូសាឡាំ)។
១៩៣. បន្តធានានូវការអនុវត្តប្រកបដោយប្រសិទ្ធភាព នៃផែនការសកម្មភាពជាតិ ស្តីពីការកាត់បន្ថយពលកម្មកុមារ ២០១៦-២០១៥ (ម៉ាល់ឌីវ)។
១៩៤. ធ្វើវិសោធនកម្មច្បាប់ជាតិ ដើម្បីធានាថា ច្បាប់នោះស្របទៅនឹងអនុសញ្ញាស្តីពីសិទ្ធិកុមារ ដោយយកចិត្តទុកដាក់ជាពិសេសទៅលើបទប្បញ្ញត្តិនានានៃក្រមព្រហ្មទណ្ឌ និងប្រព័ន្ធយុត្តិធម៌អនីតិជន (អ៊ុយរូហ្គាយ)។
១៩៥. បន្តកិច្ចខិតខំប្រឹងប្រែង ដើម្បីបង្កើនការចូលរួមរបស់ជនមានពិការភាព (ហ្វីលីពីន)។
១៩៦. អនុវត្តការគ្រប់ដណ្តប់តាមផ្លូវច្បាប់ ដែលចាំបាច់នៅក្នុងដែននៃការការពារជនមានពិការភាព ជាពិសេសដើម្បីការពារតម្រូវការ ផ្នែកអប់រំសង្គម និងសុខភាពរបស់ពួកគេ ជាពិសេស គឺតម្រូវការណាដែលចាំបាច់បំផុត (អេស្ប៉ាញ)។
១៩៧. កាត់បន្ថយភាពក្រីក្រក្នុងចំណោមជនមានពិការភាព និងសិទ្ធិ ទទួលបានបេឡាជាតិរបបសន្តិសុខសង្គមនៅឆ្នាំខាងមុខៗនេះ(អៀរឡង់)។
១៩៨. បន្តលើកកម្ពស់សិទ្ធិជនមានពិការភាព តាមរយៈផែនការយុទ្ធសាស្ត្រជាតិរបស់រដ្ឋាភិបាល (ព្រុយណេដារ៉ូសាឡឹម)។